# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានឃោសនា**
**នាយកដ្ឋានព័ត៌មាន**
លេខ:..........................

ថ្ងៃចន្ទ ៨រោច...ខែ.ពិសាខឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី...២៣.ខែ..ឧសភា ឆ្នាំ២០២២

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ បានអនុញ្ញាតជូនឯកឧត្តម នាយឧត្តមសេនីយ៍ **ហ្វាន វ៉ាន់ ហ្សាង** រដ្ឋមន្ត្រីក្រសួងការពារប្រទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅប្រទេសវៀតណាម។

នៅក្នុងជំនួបពិភាក្សានេះ **សម្តេចពិជ័យសេនា ទៀ បាញ់** អបអរសាទរចំពោះការធ្វើម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍ ស៊ីហ្គេម ឆ្នាំ២០២២ នៅប្រទេសវៀតណាមនាពេលនេះ ដំណើរការប្រកបដោយជោគជ័យ និងទទួលបានមេដាយមាស មេដាយប្រាក់ មេដាយសំរិទ្ធ ច្រើនជាងគេនៅក្នុងបណ្តាប្រទេសអាស៊ាន ដែលបានចូលរួមព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ។

**សម្តេចពិជ័យសេនា** និងឯកឧត្តម នាយឧត្តមសេនីយ៍ **ហ្វាន វ៉ាន់ ហ្សាង** បានឯកភាពបន្តអនុវត្តតាមស្មារតីជំនួបប្រាស្រ័យមិត្តភាពការពារជាតិកម្ពុជា-វៀតណាម ថ្នាក់រដ្ឋមន្ត្រី លើកទី១ កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ នៅខេត្តប៊ិញភឿក ប្រទេសវៀតណាម។ ជាមួយគ្នានេះ កងទ័ពប្រទេសទាំងពីរ កម្ពុជា-វៀតណាម ក៏បានឯកភាពបន្តដាក់ចេញទិសដៅការងារបន្ត និងប្តេជ្ញារួមគ្នាធ្វើការឱ្យកាន់តែជិតស្និទ្ធ បន្តអនុវត្តផែនការកិច្ចសហប្រតិបត្តិការ "MoU" រវាងក្រសួងការពារប្រទេសទាំងពីរកម្ពុជា-វៀតណាម ដោយផ្តោតលើកិច្ចសហប្រតិបត្តិការលើវិស័យអាទិភាពទាំងអស់ ដែលបានលើកឡើងក្នុងកិច្ចពិភាក្សា ដែលនឹងនាំមកនូវផលប្រយោជន៍ទៅវិញទៅមកដល់ប្រជាជន និងកងទ័ពប្រទេសទាំងពីរបានរួមចំណែកដល់សន្តិភាពស្ថិរភាពនិងកំណើនវិបុលភាពក្នុងតំបន់

**សម្តេចពិជ័យសេនា** និងឯកឧត្តម នាយឧត្តមសេនីយ៍ **ហ្វាន វ៉ាន់ ហ្សាង** ក៏បានធ្វើការវាយតម្លៃចំពោះសភាពការណ៍ ដែលកំពុងវិវត្តនាពេលបច្ចុប្បន្ននេះនៅក្នុងតំបន់ និងសកលលោក និងគាំទ្រជំរុញដោះស្រាយបញ្ហាមីយ៉ាន់ម៉ា ជម្លោះសមុទ្រចិនខាងត្បូង តំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិក ព្រមទាំងសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ដែលកំពុង

បង្កវិនាសកម្មយ៉ាងធំធេងដល់សម្ភារៈ ទ្រព្យសម្បត្តិ និងជីវិតមនុស្ស និងបានធ្វើឱ្យសេដ្ឋកិច្ចពិភពលោកជួបការលំបាកទៀតផង។

**សម្តេចពិជ័យសេនា** និងឯកឧត្តម នាយឧត្តមសេនីយ៍ **ហ្វាន វ៉ាន់ ហ្សាង** នឹងបន្តរួមគ្នាអនុវត្តទៅតាមលទ្ធផលដែល**សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានជំនួបជាមួយឯកឧត្តម **ផាម មិញ ជិញ** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅអំឡុងពេលស្នាក់អាស្រ័យនៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ឱ្យកាន់តែប្រសើរឡើង និងសម្រេចជោគ ជ័យថែមទៀតលើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ និងប្រវត្តិសាស្ត្រ ។ល។

**នាយកដ្ឋានព័ត៌មាន**